GMAC

Garment Manufacturers Association in Cambodia

# ការចរចាប្រាក់ឈ្នួលបានបញ្ចប់ សមាគមរោងចក្រកាត់ដេរអំពាវនាវឱ្យផ្តោតលើ ការលើកកំពស់ផលិតភាពការងារ

សមាគមរោងចក្រកាត់ដេរនៅកម្ពុជាហៅកាត់ថា GMAC បានអំពាវនាវឲ្យមានការផ្តោតជាថ្មីលើការលើកកំពស់ផលិតភាពការងារ ក្រោយការចរចាប្រាក់ឈ្នួលអប្បបរមាបានបញ្ចប់ក្នុងខែនេះ ព្រមទាំងគាំទ្រចំពោះការអំពាវនាវឲ្យអ្នកបញ្ជាទិញផលិតផលសម្លៀកបំពាក់ប្រើប្រាស់វិធីសាស្ត្របញ្ជាទិញដែលមាននិរន្តរភាពជាងមុន ។

ជាលទ្ធផលនៃការចរចាឆ្នាំនេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករក្នុងវិស័យកាត់ដេរ និងផលិតស្បែកជើង ត្រូវបានដំឡើងដល់ ១៤០ដុល្លារក្នុងមួយខែ ។ អ្នកជំនាញក្នុងវិស័យកាត់ដេរនិយាយថា ដូច្នេះឥឡូវនេះយើងចាំបាច់ត្រូវផ្តោតលើការបង្កើនផលិតភាពការងារជារួម។ យោងតាមអង្គការអន្តរជាតិខាងការងារ (ILO) ផលិតភាពការងារក្នុងវិស័យកាត់ដេរកម្ពុជាក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះបាននិងកំពុងធ្លាក់ចុះ។

លោក ខេន លូ (Ken Loo) អគ្គលេខាធិការរបស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជាបាននិយាយថា "ប្រាក់ឈ្នួលគឺជាចំណាយប្រតិបត្តិការដ៏ធំមួយសម្រាប់រោងចក្រ។ ឥឡូវនេះ យើងត្រូវមើលថាភាគីទាំងអស់ ទាំងអ្នកបញ្ជាទិញដែលផ្តោតលើការបង្កើនផលិតភាពការងារដើម្បីជួយទប់ទល់នឹងចំណាយដែលកើនឡើង ទើបអាចរក្សារោងចក្រឲ្យបន្តទៅមុខបាន ។"

ក្នុងសេចក្តីថ្លែងការណ៍មួយចេញផ្សាយក្រោយការចរចាបានបញ្ចប់ អង្គការអន្តរជាតិខាងការងារ (ILO) ក៏បានទទួលស្គាល់ផងដែរ ពីសារៈសំខាន់នៃការជំរុញលើកកំពស់ផលិតភាព និងបានអំពាវនាវឲ្យអ្នកបញ្ជាទិញសម្លៀកបំពាក់ ផ្លាស់ប្តូរទម្លាប់បញ្ជាទិញរបស់ពួកគេ គឺការដែលចង់បានតែតំលៃថោក។

អង្គការអន្តរជាតិខាងការងារបាន និងកំពុង ជំរុញឲ្យអ្នកបញ្ជាទិញផ្តល់តម្លៃឲ្យបានខ្ពស់បន្តិចទៀតដល់រោងចក្រដែលជាអ្នកផលិតផ្គត់ផ្គង់ ដើម្បីជួយឲ្យពួកគេអាចទប់ទល់នឹងចំណាយប្រតិបត្តិការដែលចេះតែកើនឡើង ជាពិសេសគឺប្រាក់ឈ្នួល។ ក្រោយការចរចាប្រាក់ឈ្នួលនៅក្នុងឆ្នាំ ២០១៤ អ្នកសេដ្ឋកិច្ចរបស់អង្គការអន្តរជាតិខាងការងារ បានប៉ាន់ស្មានថា បើអ្នកបញ្ជាទិញបង្កើនតម្លៃទិញ តែ៣ភាគរយ នោះវានឹងអាចជួយចំពោះការកើនឡើងប្រាក់ឈ្នួល និងជួយរក្សាឧស្សាហកម្មនេះមាននិរន្តរភាព ។

ទាក់ទងទៅនឹងការចរចាប្រាក់ឈ្នួលនៅក្នុងឆ្នាំនេះ ទាំងសេចក្តីថ្លែងការណ៍របស់សមាគមរោងចក្រកាត់ដេរ និងអង្គការអន្តរជាតិខាងការងារ បានអបអរសាទរចំពោះការប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យដើម្បីជាលក្ខណៈវិនិច្ឆ័យ នៅក្នុងការកំណត់កម្រិតប្រាក់ឈ្នួលអប្បបរមា ហើយបានអំពាវនាវឲ្យគ្រប់ភាគីទាំងអស់ ប្រើប្រាស់ទិន្នន័យបច្ចេកទេសឲ្យបានកាន់តែច្រើននៅក្នុងការចរចានាពេលអនាគត ។

លោក ខេន លូ បានបន្ថែមទៀតថា "វាជាការចាំបាច់ ដែលយើងប្រើប្រាស់វិធីសាស្ត្របែបវិទ្យាសាស្ត្រក្នុងការកំណត់កំរិតប្រាក់ឈ្នួល តាមរបៀបដែលយុត្តិធម៌ និងមាននិរន្តរភាព ។ យើងរីករាយ ដោយភាគីជាច្រើនបានអនុវត្តតាមយន្តការជាធរមាន ដែលធានាបាននូវការពិភាក្សាក្នុងលក្ខណៈស្ថាបនាមួយ" ។

ប៉ុន្តែ លោក ខេន លូ ក៏បានសម្តែងការសោកស្តាយផងដែរ ដែលសហជីពចំនួនបួន មិនបានធ្វើការចរចាដោយភាពស្មោះត្រង់ និងបានរំលោភលើវិធាន និងនីតិវិធីផ្ទៃក្នុងរបស់ក្រុមការងារបច្ចេកទេសត្រីភាគី នៅពេលដែលពួកគេបោះបង់ការចរចានៅ មុនពេលបោះឆ្នោតជាសម្ងាត់ ដែលជាការបំពានលើកិច្ចព្រមព្រៀងមួយដែលបានធ្វើឡើងមួយសប្តាហ៍មុនថ្ងៃចរចា ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៥

GARMENT MANUFACTURERS ASSOCIATION IN CAMBODIA